**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MIPN
IRAM

*ថ្ងៃ ព្រហស្បតិ៍ ១៣ កើត ខែភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០២២*

## សេចក្តីជូនដំណឹងស្តីពី

## ការរៀបចំសន្និសីទសារព័ត៌មានអំពីការធ្វើវិសោធនកម្មច្បាប់តំបន់ការពារ និងច្បាប់ព្រៃឈើ ដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច

ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០២២ វេលាម៉ោង២៖០០ រសៀល ដល់ម៉ោង ៥៖០០ ល្ងាច នៅទីស្នាក់ការសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា ផ្ទះលេខ ២៨ ផ្លូវលេខ ៤៦០ សង្កាត់ទូលទំពូង ២ ខណ្ឌចំការមន រាជធានីភ្នំពេញ **សម្ព័ន្ធជនជាតិដើមភាគតិច** នឹងរៀបចំសន្និសីទសារព័ត៌មានស្តីពីលទ្ធផលនៃការធ្វើវិសោធនកម្មច្បាប់តំបន់ការពារ និងច្បាប់ព្រៃឈើ ដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា។ សន្និសីទសារព័ត៌មាននេះមានគោលបំណង៖

- ដើម្បីបង្ហាញពីគោលបំណង និងដំណើរការកែប្រែ/វិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដោយមិនមានការពិគ្រោះយោបល់ដល់សហគមន៍ជនជាតិដើមភាគតិចឱ្យបានទូលំទូលាយ និងបែបយុទ្ធសាស្ត្រ។
- ដើម្បីអោយតំណាងសហគមន៍ជនជាតិដើមភាគតិចចំនួន១៦រូប មកពី១៦ អំបូរជនជាតិ និងតំណាងឱ្យ សហគមន៍ជនជាតិដើមភាគតិច ១២ ខេត្ត/ក្រុងបានធ្វើការបង្ហាញនៅគោលជំហរនិងសេចក្តីព្រួយបារម្ភណ៍ទៅលើការធ្វើវិសោធកម្មច្បាប់ព្រៃឈើ២០០២និងច្បាប់តំបន់ការពារធម្មជាតិ២០០៨តាមរយៈសេចក្តីថ្លែងការរួម។
- ដើម្បីធ្វើការបង្ហាញអំពីក្របខណ្ឌច្បាប់ពាក់ពន្ធ័នឹងជនជាតិដើមភាគកតិចដែលមិនស្របគ្នាជាមួយនឹងការធ្វើវិសោធនកម្មច្បាប់ទាំងពីរដែលមិនបានផ្តល់ផលប្រយោជន៍សមូហភាពនិង

អាចប៉ះពាល់ដល់សិទ្ធិប្រពៃណីក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ការការពារ ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រតិបត្តិជំនឿប្រពៃណីប្រកបដោយចីរភាព។

សន្និសីទសារព័ត៌មាននេះក៏នឹងមានរៀបចំតាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ Zoom និងរៀបចំផ្ទាល់នៅកន្លែងដូចមានរៀបរាប់ខាងលើ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងសារព័ត៌មានទាំងអស់ជ្រាប់ជាព័ត៌មាន។

**កំណត់សម្គាល់៖**

ទីកន្លែង៖

ផ្ទះលេខ ២៨ ផ្លូវលេខ ៤៦០ សង្កាត់ទូលទំពូង ២ ខណ្ឌចំការមន ភ្នំពេញ

ផែនទី៖

https://goo.gl/maps/NNWdUgAPjpbg8bgQ6

ពេលវេលា៖

ថ្ងៃទី ៨ ខែកញ្ញា ២០២២ វេលាម៉ោង ២៖០០ ដល់ ៥៖០០ ល្ងាច

ប្រព័ន្ធចូលរួមពីចម្ងាយ៖ Zoom

**Zoom Link**

https://us06web.zoom.us/j/87519730515?pwd=TVloSDBiRnV5TVFMMldtdE1HUStSdz09

Meeting ID: 875 1973 0515

Passcode: 150478

ទំនាក់ទំនង៖

លោក សោម គន្ធារី 011 288 251, kuntheary.som@cipocambodia.org